# កិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវរ៉ែអ៊ីលម៉ានីត (ILMENITE) នៅតំបន់អូរតាគុត ស្រុកថ្មបាំង ខេត្តកោះកុង

2 9 NOV 2005

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើនៅថ្ងៃទី រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (ហៅកាត់ថា "ក្រសួង") តំណាងឱ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (ហៅកាត់ថា "រាជរដ្ឋាភិបាល") និង ក្រុមហ៊ុន SAMNANG REA THBONG THMOR CO., LTD. ជាក្រុមហ៊ុនមួយដែលបង្កើតឡើង និងឋិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា (ហៅកាត់ថា "អ្នកចុះកិច្ចសន្យា")

- ដោយហេតុថា មាត្រា៥៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា "ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀត ដែលបានកំណត់ថាជារបស់រដ្ឋ ។ ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវកំណត់ដោយច្បាប់" ។
- ដោយហេតុថា ព្រះរាជក្រមលេខ នស/រកម/០៧០១/០៥ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ បានប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។
- ដោយហេតុថា អ្នកចុះកិច្ចសន្យាបានដាក់សំណើសុំវិនិយោគលើគំរោងសិក្សាស្រាវជ្រាវរ៉ែ អ៊ីលម៉ានីត (Ilmenite) នៅក្នុងតំបន់ អូរតាគុត ស្រុកថ្មបាំង ខេត្ត កោះកុង យោងលិខិតរបស់ក្រុមហ៊ុនលេខ 018 ចុះថ្ងៃ ទី ១២ ខែ តុលា ឆ្នាំ ២០០៥ ។
- ដោយហេតុថា អ្នកចុះកិច្ចសន្យាបានទទួលសេចក្តីយល់ព្រមជាគោលការណ៍ពីរាជរដ្ឋាភិបាល យោងលិខិតជូនដំណឹងលេខ ៣៣៤៤/០៥ ត.រ.ក ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- ដូច្នេះ តាមការព្រមព្រៀងគ្នា និងលក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីទាំងពីរបានយល់ព្រមចំពោះការផ្តល់អាជ្ញាប័ណ្ណស្វែងរុករកធនធានរ៉ែដូចតទៅ ។

# ជំពូកទី ១

## ខ្លឹមសារ និងការបកស្រាយ

**ប្រការ ១ : ខ្លឹមសារ**

១.១. កម្មវត្ថុនៃកិច្ចព្រមព្រៀងនេះគឺការសិក្សាស្រាវជ្រាវរ៉ែអ៊ីលម៉ានីត (Ilmenite) ហៅកាត់ថា "ប្រតិបត្តិការរ៉ែ" ដូចមានចែងលំអិតក្នុងកិច្ចព្រមព្រៀងនេះ ។

១.២. តំបន់ប្រតិបត្តិការរ៉ែមានផ្ទៃក្រឡាចំនួន ១២០ ( មួយរយម្ភៃ)គីឡូម៉ែត្រក្រឡា ដែលឋិតនៅក្នុងតំបន់ **អូរនាគុត ស្រុកថ្មសាំង ខេត្តកោះកុង** ហើយដែលកូអ័រដោណេនៃតំបន់នេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ ១ និងផែនទីទីតាំងក្នុងឧបសម្ព័ន្ធ ២ ដូចមានភ្ជាប់មកជាមួយនេះហៅកាត់ថា "**តំបន់កិច្ចសន្យា**" ។

១.៣ រ៉ែអ៊ីលម៉ានីត (Ilmenite) នៅក្នុងកិច្ចព្រមព្រៀងនេះ ហៅកាត់ថា "**រ៉ែ**" ។

១.៤ ក្នុងករណីអ្នកចុះកិច្ចសន្យាបានរកឃើញរ៉ែផ្សេងទៀតក្រៅពីរ៉ែអ៊ីលម៉ានីត (Ilmenite) ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ ហើយមានបំណងធ្វើអាជីវកម្មជីកយករ៉ែទាំងនោះ អ្នកចុះកិច្ចសន្យាត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណរ៉ែពាក់ព័ន្ធផ្សេងទៀតដូចបានចែងនៅក្នុងបទបញ្ញត្តិ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

១.៥ អ្នកចុះកិច្ចសន្យាត្រូវទទួលខុសត្រូវចំពោះមុខក្រសួងនូវការអនុវត្តន៍ប្រតិបត្តិការរ៉ែ ដោយអនុលោមតាមប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ និងក្រោមការត្រួតពិនិត្យរបស់ក្រសួង ។ អ្នកចុះកិច្ចសន្យា ជាអង្គភាពស្របច្បាប់មួយ ដែលមានសិទ្ធិអនុវត្តប្រតិបត្តិការរ៉ែដែលបានគ្រោងទុកនៅក្នុងតំបន់កិច្ចសន្យាក្នុងរយៈពេលនៃអាជ្ញាប័ណ្ណស្វែងរុករករ៉ែ ។

១.៦ អ្នកចុះកិច្ចសន្យាមិនមែនជាម្ចាស់កម្មសិទ្ធិលើតំបន់កិច្ចសន្យា ដែលបានកំណត់ក្នុងប្រការ ១.២ ខាងលើនេះឡើយ លើកលែងតែតំបន់ណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ភូមិបាលដែលមានជាធរមាន ។

១.៧ អ្នកចុះកិច្ចសន្យាត្រូវផ្តល់ដើមទុន បច្ចេកវិទ្យា និង កំលាំងពលកម្មចាំបាច់ ដើម្បីអនុវត្តប្រតិបត្តិការរ៉ែដែលបានគ្រោងទុក លើកលែងតែមានសេចក្តីចែងផ្សេងទៀតក្នុងកិច្ចព្រមព្រៀងនេះ ។

១.៨ អ្នកចុះកិច្ចសន្យាត្រូវអនុវត្តប្រតិបត្តិការរ៉ែដែលបានគ្រោងទុកដោយទទួលការខាតបង់ និងចំណាយដោយខ្លួនឯងផ្ទាល់ លើកលែងតែមានសេចក្តីចែងផ្សេងទៀតក្នុងកិច្ចព្រមព្រៀងនេះ ។

១.៩ កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាន ចាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាដោយភាគីទាំងពីរហៅកាត់ថា "**កាលបរិច្ឆេទធរមាន**" ។

---